ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០០៣.....សហវ.--

រាជធានីភ្នំពេញ, ថ្ងៃទី...០៧...ខែ...កញ្ញា.....ឆ្នាំ២០០៧

# សារាចរណែនាំបន្ថែម លើសារាចរណែនាំ

## ស្តីពី

## ការចំណាយតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន

## (សំរាប់ថវិកាតាមកម្មវិធី)

ក្នុងគោលបំណងអោយការអនុវត្តន៍ចំណាយតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទានរបស់ថវិកាតាមកម្មវិធីដំណើរការដោយភាពរលូននិងមានការឯកភាពគ្នាទូទាំងប្រទេសនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមធ្វើការកែសំរួលនូវចំណុចមួយ ចំនួននៃសារាចរណែនាំលេខ ០១៤សហវ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការចំណាយតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទានដូចខាងក្រោម:

**១-អំពីតារាងឧបសម្ព័ន្ធត្រូវបង្កើតរដ្ឋទេយ្យបុរេប្រទានថវិកាតាមកម្មវិធី:**

ក្នុងតារាងឧបសម្ព័ន្ធបង្កើតរដ្ឋទេយ្យបុរេប្រទានថវិកាតាមកម្មវិធី ត្រូវជ្រើសរើសយកមាតិកាចំណាយតាម គណនី និងអនុគណនីនៃជំពូក **៦០ -៦១ -៦២ -៦៤ -៦៥** ដែលជាចំណាយចាំបាច់សំរាប់កិច្ចដំណើរការរដ្ឋបាល ដោយដកចេញចំពោះខ្ទង់ចំណាយទាំងឡាយ ដែលសាមីក្រសួង-ស្ថាប័ន-មន្ទីរ-អង្គភាពទុកសំរាប់ចំណាយតាម នីតិវិធីទូទាត់ត្រង់ ។

**២-អំពីទឹកប្រាក់នៃជុំបង្វិលសំរាប់រដ្ឋទេយ្យបុរេប្រទានថវិកាតាមកម្មវិធី:**

ចំពោះទឹកប្រាក់ជុំបង្វិលសំរាប់រដ្ឋទេយ្យបុរេប្រទានថវិកាតាមកម្មវិធីគឺ ត្រូវគិត១ភាគ៤នៃទឹកប្រាក់សរុបសំរាប់បង្កើតរដ្ឋទេយ្យបុរេប្រទានថវិកាតាមកម្មវិធី ។

**៣-អំពីកិច្ចដំណើរការនៃរដ្ឋទេយ្យបុរេប្រទានថវិកាតាមកម្មវិធី:**

ចំនួនទឹកប្រាក់សំរាប់មួយគោលការណ៍ចំណាយ (មួយប័ណ្ណចំណាយ) មិនត្រូវបានកំណត់ដូចថវិកាមិនមែនតាមកម្មវិធីនោះទេ គឺត្រូវបានធ្វើការទូទាត់ទៅតាមការជាក់ស្តែង ។

ចំពោះចំណុចទាំងឡាយផ្សេងៗទៀត ដែលមានចែងនៅក្នុងសារាចរណែនាំលេខ ០១៤ សហវ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ គឺនៅតែជាធរមានដដែល ។

លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសារាចរណែនាំបន្ថែមនេះត្រូវចាត់ទុកជានិរាករណ៍ ។

ទទួលបានសារាចរណែនាំបន្ថែមនេះ សូមគ្រប់ក្រសួង-ស្ថាប័ន-មន្ទីរ-អង្គភាព និងសាលាខេត្ត-ក្រុងត្រូវ គោរព អនុវត្តអោយទទួលបានលទ្ធផលល្អប្រសើរ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

<u>ចំលងជូនៈ</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី

  " ដើម្បីជូនជ្រាប "
- គ្រប់ក្រសួង-ស្ថាប័ន-រដ្ឋលេខាធិការដ្ឋាន
- គ្រប់ខេត្ត-ក្រុង

  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ